**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ:៦៦៩

ចុះថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ ២០១៧

**សាលក្រមព្រហ្មទណ្ឌ**

លេខ: ១៤ (ច)

ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៨

# តាងនាមប្រជារាស្ត្រខ្មែរ

*សាលាដំបូងខេត្តកំពង់ឆ្នាំង បានបើកសវនាការ*

ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០១៨

*ដោយមានសមាសភាពជំនុំជម្រះ៖*

១-លោក [redacted] *ចៅក្រមជំនុំជម្រះ*

២-លោក [redacted] *តំណាងអយ្យការ*

៣-លោក [redacted] *ក្រឡាបញ្ជីសវនាការ*

***ដើម្បីធ្វើការជំនុំជម្រះលើជនជាប់ចោទ:***

១-ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ អ៊ិតស្កុតម៉ូតូ ទីកន្លែងកំណើតភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ទីកន្លែងសព្វថ្ងៃនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted]) ម្តាយមិនស្គាល់ (ស) នៅលីវ ទោសពីមុនគ្មាន **(ឃុំខ្លួនថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៧)** ។

ត្រូវជាប់ចោទពីបទ: រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## ការប្រព្រឹត្តរបស់ជនជាប់ចោទមានដូចតទៅ:

កាលពីថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង១១ និង ០០នាទី នីចំណុចភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កើតមានករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលបង្កឡើងដោយឈ្មោះ [redacted] បានយកថ្នាំញៀនចំនួន ០១កញ្ចប់ទៅលក់ឲ្យគេនៅក្បែរផ្ទះរបស់ខ្លួនក្នុងតម្លៃ ៣០ ០០០ (បីម៉ឺន)រៀល ហើយត្រូវបានសមត្ថកិច្ចចាប់ឃាត់ខ្លួន និងឆែកឆេរកឃើញថ្នាំញៀនចំនួន ០៩កញ្ចប់នៅនិងខ្លួន ព្រមទាំងឧបករណ៍ប្រើប្រាស់មួយចំនួនទៀត។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ: ២០១ /១៨ ចុះថ្ងៃទី ១៨ ខែ មករា ឆ្នាំ២០១៨ របស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ឆ្នាំង ។



Scanned by CamScanner

បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខៈ ១០២ /១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរ។

បានឃើញ ដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខៈ ១៧៥ /១៨ ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ២០១៨ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

## នាពេលសវនាការ

-ចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថាៈ កាលពីថ្ងៃកើតហេតុ ខ្លួនបានលក់ថ្នាំញៀនឲ្យទៅគេ ចំនួន ៣០.០០០(សាមសិបពាន់) រៀល ហើយកន្លងមកខ្លួនធ្លាប់លក់ឲ្យគេបានចំនួន ០៣ ទៅ ០៤ ដងមកហើយ ចំណែកគ្រឿងញៀនខ្លួនទិញពីឈ្មោះ [redacted] ក្នុងតម្លៃ ១៥០.០០០(មួយរយហាសិបពាន់)រៀល យកមកបំបែកបានពី ០៧ ទៅ ០៨ កញ្ចប់ ក្នុងមួយថ្ងៃលក់បាន ០២ កញ្ចប់ ។

-អំណានចម្លើយមន្ត្រីនគរបាលឈ្មោះ [redacted] បានឆ្លើយថាៈ កាលពីថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០១៧ វេលាម៉ោង ១១ព្រឹក សមត្ថកិច្ចបានចាប់ខ្លួនឈ្មោះ [redacted] នៅផ្ទះភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ការចាប់ខ្លួនឈ្មោះ [redacted] នេះគឺបានប្រើប្រាស់កម្លាំងផ្ទាក់ឲ្យទៅទិញថ្នាំចំនួន ០១កញ្ចប់តម្លៃ ៣០.០០០ (បីម៉ឺន) រៀល ក្រោយពីទិញបាន ក៏ចូលទៅចាប់តែម្តង ពេលចាប់ខ្លួនឆែកឆេរកឃើញថ្នាំនៅនឹងខ្លួន ចំនួន ០៩ កញ្ចប់ទៀត សរុប ១០កញ្ចប់ ដកយកទូរស័ព្ទដៃម៉ាក ចុចពិល ០១គ្រឿង និងឧបករណ៍សម្រាប់ជក់មួយចំនួន ក្រៅពីនោះគ្មានទេ កម្លាំងដែលចូលទិញមិនចាំឈ្មោះទេ ចំពោះលិខិតប្រើប្រាស់កម្លាំងខ្លួនក៏មិនបានដឹងដែរ ហើយឈ្មោះ [redacted] នេះពុំដែលមានឈ្មោះក្នុងបញ្ជីទេ តែជននេះអាចលក់យូរមកហើយ ពីព្រោះមានម៉ូយមកពីឆ្ងាយៗ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថាៈ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទៈរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ។

-ជនជាប់ចោទឈ្មោះ [redacted] បានសំណូមពរចុងក្រោយថាៈ សូមឲ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ
ក្រោយពីបានស្តាប់អំណានចម្លើយមន្ត្រីនគរបាលយុត្តិធម៌
ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ
ក្រោយពីបានស្តាប់សំណូមពរចុងក្រោយរបស់ជនជាប់ចោទ
ក្រោយពីបានពិនិត្យ ភស្តុតាង ឯកសារទាំងរស់ក្នុងសំណុំរឿង
ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned by CamScanner

# <u>សាលាដំបូងខេត្តកំពង់ឆ្នាំង យល់ឃើញថា:</u>

១-តុលាការបានទទួលបណ្តឹងតាមដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ១០២ /១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង ដែលបានបញ្ជូនជនជាប់ចោទ ១-ឈ្មោះ[redacted]ក តុលាការដើម្បីជំនុំជម្រះពីបទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-ចម្លើយជនជាប់ចោទឈ្មោះ[redacted]ថា: កាលពីថ្ងៃកើតហេតុ ខ្លួនបានលក់គ្រឿងញៀនទៅឲ្យគេក្នុងតម្លៃ ៣០.០០០(សាមសិបពាន់)រៀល ពិតប្រាកដមែន ដោយក្នុងនោះគ្រឿងញៀនខ្លួនទិញពីគេក្នុងតម្លៃ ១៥០.០០០ (មួយរយហាសិបពាន់) រៀល ។

៣-ចម្លើយមន្ត្រីនគរបាលឈ្មោ[redacted]ថា: កាលពីថ្ងៃកើតហេតុ ខ្លួនបានប្រើប្រាស់កម្លាំងទិញគ្រឿងញៀនពីឈ្មោ[redacted]តម្លៃ ៣០.០០០(សាមសិបពាន់)រៀល ហើយពេលប្រតិបត្តិការដកហូតបានគ្រឿងញៀនចំនួន ០៩ កញ្ចប់បន្ថែមទៀត ។

៤-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា: មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើឈ្មោះ[redacted]បទ រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ស្នើសូមតុលាការមេត្តាពិចារណាទៅតាមច្បាប់ ការប្តឹងសុំនេះតុលាការអាចពិចារណាព្រោះតាមអង្គហេតុ និងការសារភាពរបស់ជនជាប់ចោទពិតជាមានករណី រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រាកដមែន គប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៥-ឆ្លងកាត់សវនាការ ការពិភាក្សាដេញដោល ចម្លើយជនជាប់ចោទ ចម្លើយមន្ត្រីជំនាញ ការប្តឹងសុំរបស់តំណាងអយ្យការព្រមទាំងភស្តុតាងនានាក្នុងសំណុំរឿងតុលាការពិចារណាឃើញថាជនជាប់ចោទពិតជាបានរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ព្រោះជនជាប់ចោទបានសារភាពនូវទង្វើរបស់ខ្លួនស៊ីសង្វាក់ទៅនឹងពេលប្រតិបត្តិការសមត្ថកិច្ចបានឃាត់បានគ្រឿងញៀន និងឧបករណ៍ជក់គ្រឿងញៀនផងដែរ ដូច្នេះគប្បីតុលាការផ្តន្ទាទោសជនជាប់ចោទតាមច្បាប់ ។

៦-មានភស្តុតាងដាក់បន្ទុក និងពិរុទ្ធភាពគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ[redacted]ភទប្រុស អាយុ ២០ ឆ្នាំ ។

ពីបទ: រក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧-វត្ថុតាងរួមមាន:

៧.១-ទូរស័ព្ទដៃចំនួន ០១ គ្រឿង គប្បីតុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ។



Scanned by CamScanner

៧.២-ថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ១០ កញ្ចប់ស្មើនឹង ១,០៩ ក្រាម និងឧបករណ៍ជក់មួយចំនួន គប្បីតុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

៨-ជនជាប់ចោទជានីតិជន ដែលមិនមានភស្តុតាងបញ្ជាក់ថាកើតមានវិបល្លាសស្មារតីទេ ដូច្នេះជននេះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើប្រព្រឹត្តរបស់ខ្លួន ។អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ បំផ្លាញដល់សុខភាពខ្លួនឯងផ្ទាល់ ប៉ះពាល់ដល់ជីវភាពគ្រួសារ និងឈានដល់ការបង្កការលំបាកជាច្រើនទៀតដល់សង្គមជាតិ ដែលកើតឡើងដោយសារធាតុឥទ្ធិពលនៃគ្រឿងញៀន ។

## <u>ហេតុដូច្នេះសម្រេច</u>

១-ផ្តន្ទាទោសជនជាប់ចោទ:

-ឈ្មោះ [redacted] ភេទប្រុស អាយុ ២០ឆ្នាំ ដាក់ពន្ធនាគារចំនួន ០៣(បី) ឆ្នាំ ។

ពីបទៈរក្សាទុក ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិផ្សារលើ សង្កាត់ផ្សារឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០១៧ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២-វត្ថុតាងរួមមាន:ទូរស័ព្ទដៃចំនួន ០១ គ្រឿង តុលាការរឹបអូសជាទ្រព្យសម្បត្តិរដ្ឋ ចំណែកថ្នាំញៀនប្រភេទម៉ាទឹកកកចំនួន ១០ កញ្ចប់ស្មើនឹង ១,០៩ ក្រាម និងឧបករណ៍ជក់មួយចំនួន តុលាការធ្វើការរឹបអូស និងបំផ្លាញចោល ។

៣-សាលក្រមនេះជំនុំជម្រះនៅថ្ងៃទី ២៧ ខែ មិនា ឆ្នាំ ២០១៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៨ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ។

បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ៕

ក្រឡាបញ្ជីសវនាការ

[redacted]

ចៅក្រមជំនុំជម្រះ

[redacted]



Scanned by CamScanner